ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម
AGRICULTURAL AND RURAL DEVELOPMENT BANK
ដើម្បីកសិករនិងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម

# គម្រោងអាជីវកម្ម

## ចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ បាយអូប្លុក

## Red Tilapia fish farming by Biofloc system



រៀបចំដោយ

**គណៈកម្មការគាំទ្រគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃ**

**ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (អេ.អ.ឌី.ប៊ី)**

ខែសីហា ឆ្នាំ២០២៣

# មាតិកា

១-សេចក្តីផ្តើម....................................................................................................................1
២-លក្ខណៈជីវសាស្ត្ររបស់ត្រីទីឡាព្យាក្រហម................................................................................1
៣-បច្ចេកទេសក្នុងការចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ Biofloc...........................................4
៣.១. ការសាងសង់អាង និងរៀបចំប្រព័ន្ធខ្យល់.......................................................................4
៣.១.១. ការជ្រើសរើសទីតាំង..............................................................................................4
៣.១.២. សម្ភារៈសម្រាប់សង់អាង........................................................................................5
៣.១.៣. ការសាងសង់អាង...................................................................................................5
៣.១.៤. ការរៀបចំប្រព័ន្ធខ្យល់............................................................................................5
៣.១.៥. ការគណនាមាឌអាង និងបរិមាណទឹកក្នុងអាង.........................................................6
៣.១.៦. ការបញ្ចូលទឹក និងកែគុណភាពទឹកមុនពេលដាក់កូនត្រី..............................................6
៣.២. ការជ្រើសរើសកូនត្រីពូជ..............................................................................................6
៣.៣. ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹម.............................................................................................7
៣.៤. ការលែងកូនត្រីពូជ.........................................................................................................7
៣.៥. ការផ្តល់ចំណី..................................................................................................................7
៣.៦. ការគ្រប់គ្រង និងថែទាំ...................................................................................................9
៣.៧. ការបង្ការ និងការព្យាបាលជំងឺត្រី..................................................................................10
៣.៨. ការប្រមូលផល...............................................................................................................11
៤-គម្រោងចំណាយលើការចិញ្ចឹមត្រីទីឡាព្យាតាមប្រព័ន្ធ ឆាយអូប្លុក.............................................12
៤-១-គម្រោងចិញ្ចឹម.................................................................................................................12
៤-២-ការចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង..........................................................12
៤-៣-ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹម១វគ្គ.............................................................................13
៤-៤-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់.......................................................................15
៤-៥-ការវិភាគលើខ្សែច្រវាក់តម្លៃ.............................................................................................16
៥-ហានិភ័យ-បញ្ហាប្រឈម......................................................................................................16
៦-សេចក្តីសន្និដ្ឋាន................................................................................................................17
ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ.....................................................................................18

## ១-សេចក្តីផ្តើម

ត្រីទីឡាព្យាក្រហមគឺជាប្រភេទត្រីទឹកសាប ងាយស្រួលក្នុងការចិញ្ចឹម ធន់នឹងជំងឺ ស៊ីចំណីចម្រុះ ជាផលិតផលមួយដ៏សំខាន់ក្នុងវិស័យវារីវប្បកម្មនៅកម្ពុជា ដែលកសិករភាគច្រើនចិញ្ចឹមជាលក្ខណៈគ្រួសារតាមបែបពាក់កណ្តាលប្រពលវប្បកម្ម និងប្រពលវប្បកម្មនៅក្នុងស្រះ បែរ ស៊ង ស្រែ អាង តង់ប្លាស្ទីកដោយអាចចិញ្ចឹមទោល និងចិញ្ចឹមចម្រុះជាមួយប្រភេទត្រីផ្សេងៗទៀត។ បច្ចុប្បន្នត្រីទីឡាព្យាក្រហមត្រូវបានកសិករមួយចំនួនចិញ្ចឹមតាមបច្ចេកទេសថ្មីហៅថា **ប្រព័ន្ធ បាយអូហ្លុក** (Biofloc System) ដែលការចិញ្ចឹមមានលក្ខណៈទំនើបជាងការចិញ្ចឹមតាមបែបធម្មតា និងត្រូវបានផ្សព្វផ្សាយក្នុងវិស័យវារីវប្បកម្ម។ Bio floc ជាប្រព័ន្ធចិញ្ចឹមត្រីមានថ្លៃដើមផលិតទាប ត្រីមានគុណភាពខ្ពស់ ដោយប្រើរយៈពេលខ្លី ទទួលបានផលច្រើន ងាយស្រួលថែទាំ ប្រើទឹកតិច ចំណេញទាំងចំណី និងទីកន្លែង។ **បច្ចេកវិទ្យា Biofloc គឺជាប្រព័ន្ធបំប្លែងកាកសំណល់ចេញពីទឹក កែប្រែគុណភាពទឹក បង្កើតបានពពួកបាក់តេរីល្អៗទៅសម្អាតបាក់តេរីមិនល្អដែលមានគ្រោះថ្នាក់ និងធ្វើឱ្យទឹកមានលំនឹងគុណភាពល្អ។**

ដោយសារប្រព័ន្ធ Bio floc គឺជាបច្ចេកវិទ្យាថ្មី កសិករចាំបាច់ត្រូវធ្វើការសិក្សាស្វែងយល់ឱ្យបានច្បាស់ជាមុនអំពីបច្ចេកទេសចិញ្ចឹមរួមមាន÷ ១.តើអ្វីទៅជាប្រព័ន្ធ Biofloc? ២.តើត្រូវរៀបចំប្រព័ន្ធទឹក និងខ្យល់ដូចម្តេច ៣.បច្ចេកទេសផលិត FCO (Fermented of Carbon Organic) ដើម្បីបង្កើតកម្រិត floc និងការគ្រប់គ្រងគុណភាពទឹកឱ្យបានសមស្រប ៤.តើបណ្តុះបាក់តេរីដើម្បីអ្វី និងធ្វើដូចម្តេចទើបដឹងថាមានបាក់តេរីនៅក្នុងទឹក? ៥.នៅពេលកម្រិតប៉េហាស់ និងអាល់កាឡាំងប្រែប្រួលត្រូវធ្វើដូចម្តេច? នៅពេលកម្រិត TSS (Total Suspended Solids) ច្រើនពេកឬតិចពេកត្រូវធ្វើដូចម្តេច?។ ដូចគ្នានឹងអាជីវកម្មផ្សេងទៀតដែរ អាជីវកម្មចិញ្ចឹមត្រីតម្រូវឱ្យកសិករគិតគូឱ្យបានច្បាស់អំពីផែនការអាជីវកម្ម និងទីផ្សារ។

## ២-លក្ខណៈជីវសាស្ត្ររបស់ត្រីទីឡាព្យាក្រហម

ត្រីទីឡាព្យាក្រហមដែលកសិករនិយមចិញ្ចឹមនៅកម្ពុជាមានឈ្មោះវិទ្យាសាស្ត្រថា Oreochromis sp. គឺជាប្រភេទត្រីទឹកសាបស្ថិតក្នុងអម្បូរ Cichlidae មានប្រភពពីប្រទេសតៃវ៉ាន់។ ត្រីទីឡាព្យាក្រហមជាត្រីកូនកាត់ដែលបង្កាត់ចេញពីត្រីទីឡាព្យាខ្មៅម៉ូសំប៊ិច (Oreochromis mossambicus) ជាមួយនឹងត្រីទីឡាព្យាក្រហមតៃវ៉ាន់ប្រភេទ Taiwanese red tilapia ឬត្រីទីឡាព្យាខ្មៅម៉ូសំប៊ិច ជាមួយនឹងត្រីទីឡាព្យាក្រហមហ្វីលីពីន (Oreochromis niloticus)។ ដូចនេះ ត្រីទីឡាព្យាក្រហមជាត្រីដែលមានសម្បុរពណ៌ក្រហម និងបានអភិវឌ្ឍន៍ជាបន្តបន្ទាប់រហូតមកជាការចិញ្ចឹមត្រីទីឡាព្យាឈ្មោលសុទ្ធ ដែលផ្តល់ទិន្នផលខ្ពស់ជាងការចិញ្ចឹមចម្រុះ (ញីឈ្មោលលាយគ្នា)។

-ឈ្មោះជាភាសាខ្មែរ÷ **ទីឡាព្យាក្រហម**

-ឈ្មោះជាភាសាអង់គ្លេស÷ **Red Tilapia**

-ឈ្មោះវិទ្យាសាស្ត្រ÷ **Oreochromis sp.**

-ស្ថិតក្នុងអម្បូរ ÷ **Cichlidae**



❖ **រូបរាង÷**

- ជាប្រភេទត្រីស្រកា មានដងខ្លួនសំប៉ែតបញ្ឈរ ស្រដៀងត្រីកន្ត្រប់ កន្ធរ ឬត្រីក្រាញ់
- មានមាត់ធំប្រហែល ១ភាគ៩នៃដងខ្លួន ដែលមានអំណោយផលក្នុងការភ្ញាស់ពងក្នុងមាត់
- មានភ្នែកធំៗ ហើយនៅលើក្បាលមានស្រកាតូចៗពណ៌ក្រហម និងផ្នែកពោះពណ៌ប្រាក់
- ជាប្រភេទត្រីមានព្រុយរឹងមាំ ដូចជា ព្រុយខ្នង កន្ទុយ គូទ ពោះ ទ្រូង
- ព្រុយគូ÷ មានព្រុយទ្រូង និងព្រុយចំហៀងខ្លួន
- ព្រុយសេស÷ មានព្រុយខ្នង ព្រុយកន្ទុយ និងព្រុយគូទ
- ការលូតលាស់ត្រីទីឡាព្យាក្រហម គឺត្រីឈ្មោលធំធាត់លឿនជាងត្រីញី

**ភាពខុសគ្នានៃពណ៌សម្បុររបស់ត្រីទីឡាព្យាក្រហម**



❖ **មជ្ឈដ្ឋានទឹករស់នៅ÷** ក្នុងធម្មជាតិត្រីទីឡាព្យាក្រហមអាចរស់នៅក្នុងមជ្ឈដ្ឋានទឹកដូចខាងក្រោម÷

- កម្រិត pH សមស្របចន្លោះពី ៦.៥ ទៅ ៨.៥
- កម្រិតអុកស៊ីសែនរលាយក្នុងទឹក ២ ទៅ ៣ មីលីក្រាម/លីត្រទឹក
- សីតុណ្ហភាពសមស្របចន្លោះពី ២៥ ទៅ ៣៥អង្សាសេ
- កម្រិតថ្លានៃទឹកចន្លោះពី ៣០ ទៅ ៤៥ សង់ទីម៉ែត្រ

❖ **ចរិកស៊ីចំណី÷**

ត្រីទីឡាព្យាក្រហម ជាប្រភេទត្រីស៊ីចំណីចម្រុះនៅស្រទាប់ទឹកលើ កណ្ដាល និងស្រទាប់បាត។ ក្រៅពីចំណីសម្រេចក្រុមហ៊ុន វាអាចស៊ីពពួកសត្វប្លង់តុង សារាយ គ្រាប់ធញ្ញជាតិ សត្វល្អិត ចកបាយទា បន្លែ កន្ទក់ ពោត ចុងអង្ករ កាកសំណល់ផ្ទះបាយ ជន្លេន។ ការចិញ្ចឹមតាមបែបប្រពលវប្បកម្មអាចទទួលបានទិន្នផលខ្ពស់គួរសម ពីព្រោះកសិករអាចធ្វើការកែច្នៃចំណីផ្សំចេញពីវត្ថុធាតុដើមក្នុងស្រុកដែលមានតម្លៃទាប ជំនួសឱ្យការប្រើចំណីគ្រាប់ពីរោងចក្របាន។ ប៉ុន្តែចំណីផ្សំគួរកែច្នៃជាគ្រាប់ និងអណ្ដែតទឹក ដើម្បីងាយស្រួលតាមដានសកម្មភាពស៊ីចំណីរបស់ត្រី អាចគ្រប់គ្រងបរិមាណចំណីលើសឬខ្វះ និងអាចគ្រប់គ្រងគុណភាពទឹកបានល្អ។




❖ **ការលូតលាស់÷**

ត្រីទីឡាព្យាក្រហមឈ្មោលធំធាត់លឿនជាងត្រីញី។ ការលូតលាស់ធំធាត់របស់ត្រីទីឡាព្យាអាស្រ័យលើបរិស្ថានទឹក ចំណីដែលបានផ្ដល់ ដង់ស៊ីតេដាក់កូនត្រី សីតុណ្ហភាព និងបច្ចេកទេសថែទាំ។ ការចិញ្ចឹមបែបប្រពលវប្បកម្មត្រីលូតលាស់ធំធាត់ជាងការចិញ្ចឹមតាមបែបពាក់កណ្ដាលប្រពលវប្បកម្ម និងការចិញ្ចឹមចម្រុះជាមួយប្រភេទត្រីផ្សេងៗ។ ការចិញ្ចឹមក្នុងវារីវប្បកម្ម ត្រីលូតលាស់លឿនជាងនៅក្នុងធម្មជាតិ ដែលអាចមានទម្ងន់ចន្លោះពី ០.៤-០.៦គ.ក/ក្បាលឬធំជាងនេះ ក្រោយពេលចិញ្ចឹមបាន ០៥ខែ ដោយផ្ដល់ចំណីសម្រេចក្រុមហ៊ុនគ្រប់គ្រាន់ និងមានការថែទាំគុណភាពទឹកបានសមស្រប។

❖ **ការបន្តពូជ÷**

ត្រីទីឡាព្យាក្រហម ជាប្រភេទត្រីឆាប់ធំពេញវ័យ អាចបន្តពូជបាននៅពេលមានអាយុចាប់ពី ៤ ឬ ៥ខែឡើងទៅ និងទម្ងន់ចន្លោះពី ៥០-១០០ក្រាមក្នុងមួយក្បាល។ ដោយឡែកនៅក្នុងកសិដ្ឋានផលិតកូនពូជ កសិករគួរជ្រើសរើសមេពូជទម្ងន់ចាប់ពី ១៥០ក្រាមឡើងទៅទើបល្អ។ ត្រីទីឡាព្យាក្រហមអាចបន្តពូជឬពងកូនបានច្រើនដងរហូតដល់១០-១២ដងក្នុងមួយឆ្នាំ ប៉ុន្តែវាអាចទម្លាក់ពងបានចំនួនតិចគឺចន្លោះពី ១៥០-២,០០០គ្រាប់ពងប៉ុណ្ណោះក្នុងមួយដង ដោយអាស្រ័យលើទម្ងន់ត្រីមេពូជ។

ត្រីទីឡាព្យាក្រហមមេភ្ញាស់ពងនៅក្នុងមាត់របស់វាក្នុងរយៈពេលពី៣-៥ថ្ងៃ។ ក្រោយពេលត្រីញាស់ត្រីមេនៅបណ្តើរកូនពី ៨-១០ថ្ងៃ ទើបឈប់ និងអាចបន្តពូជទៀតបាន។



**៣-បច្ចេកទេសចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ Biofloc ÷**

បច្ចេកវិទ្យា Biofloc គឺជាបច្ចេកទេសនៃការកែលម្អគុណភាពទឹកដោយធ្វើឱ្យមានតុល្យភាពរវាងសារធាតុកាបូន និងអាសូត ដោយពឹងផ្អែកលើការលូតលាស់របស់អតិសុខុមប្រាណនៅក្នុងទឹក ជួយដល់ការធំធាត់របស់ត្រី និងមិនប៉ះពាល់ដល់បរិស្ថាន។ ប្រព័ន្ធ Biofloc ចំនួនពីរដែលកំពុងអនុវត្តន៍នៅកម្ពុជា÷

១-Biofloc ប្រើប្រាស់ពន្លឺព្រះអាទិត្យ (Outdoor)÷ គឺជាការចិញ្ចឹមនៅផ្នែកខាងក្រៅ និងក្នុងផ្ទះកញ្ចក់ដោយប៉ះពន្លឺព្រះអាទិត្យ ដែលសមាសធាតុអាល់កាឡាំង និងបាក់តេរី ដំណើរការគ្រប់គ្រងគុណភាពទឹកបណ្តាលឱ្យទឹកក្នុងអាងមានពណ៌បៃតង ឬហៅថា “Green Water Biofloc System” ។

២-Biofloc មិនប្រើប្រាស់ពន្លឺព្រះអាទិត្យ (Indoor)÷ គឺជាការតម្លើងអាងចិញ្ចឹមនៅក្នុងអគារបិទជិតមិនប៉ះផ្ទាល់ជាមួយពន្លឺព្រះអាទិត្យដែលមានតែបាក់តេរីដំណើរការគ្រប់គ្រងគុណភាពទឹក និងបណ្តាលឱ្យទឹកមានពណ៌ត្នោតស្រាល ឬហៅថា “Brown Water Biofloc System” ។



Biofloc ប្រើប្រាស់ពន្លឺព្រះអាទិត្យ (Outdoor)



Biofloc មិនប្រើប្រាស់ពន្លឺព្រះអាទិត្យ (Indoor)

## ៣.១. ការសាងសង់អាង និងរៀបចំប្រព័ន្ធខ្យល់÷

### *៣.១.១. ការជ្រើសរើសទីតាំង÷*

- គួរជ្រើសរើសទីតាំងដែលនៅជិតប្រភពទឹក ដែលអាចសន្សំសំចៃថ្លៃបូមទឹកចេញ-ចូល និងមិនប៉ះពាល់ដោយទឹកជំនន់។
- គ្មានដើមឈើធំៗនៅជុំវិញ និងមានពន្លឺថ្ងៃចាំងចូលគ្រប់គ្រាន់ (Outdoor)
- មានអគ្គិសនីគ្រប់គ្រាន់

*(អាចប្រើប្រាស់ទឹកអណ្តូង ឬទឹកម៉ាស៊ីនបាន ប៉ុន្តែមិនអាចប្រើផ្ទាល់បានទេ តម្រូវឱ្យធ្វើការកែគុណភាពទឹកជាមុនសិន)*

### *៣.១.២. <u>សម្ភារៈសម្រាប់សង់អាង</u> ÷*





- ដែកសំប៉ែត ឬមូលសម្រាប់ធ្វើគ្រោងឆ្អឹងអាង
- ស័ង្កសីកម្ពស់ ១.២ម ហ៊ុមការពារកៅស៊ូតង់
- កៅស៊ូតង់ សម្រាប់ស្តុកទឹកចិញ្ចឹមត្រី
- ទុយោជ័រសម្រាប់ធ្វើប្រព័ន្ធបញ្ចេញបញ្ចូលទឹក
- វ៉ាន់បិទ-បើកទឹក
- កែងបញ្ចេញបញ្ចូលទឹក
- ម៉ូទ័រខ្យល់
- ទុយោជ័រទន់សម្រាប់រៀបចំប្រព័ន្ធខ្យល់
- វ៉ាន់បិទ-បើកខ្យល់
- ថ្មពពុះខ្យល់

### *៣.១.៣. <u>ការសាងសង់អាង</u> ÷*

ជំហានទី១÷ សម្អាតទីតាំងដី និងកាយដីឱ្យមានផតរាងបាតខ្ទះនៅផ្ទៃកកណ្តាល

ជំហានទី២÷ រៀបចំផ្សារគ្រោងឆ្អឹងដែក និងភ្ជាប់ស័ង្កសីការពារកៅស៊ូតង់

ជំហានទី៣÷ រៀបចំប្រព័ន្ធទុយោបញ្ចេញទឹកនៅបាតអាង



ជំហានទី៤÷ រៀបចំតម្លើងកៅស៊ូតង់

ជំហានទី៥÷ ចោះប្រព័ន្ធបញ្ចេញទឹកនៅបាតអាង

ជំហានទី៦÷ រៀបចំប្រព័ន្ធបញ្ចូលទឹក

ជំហានទី៧÷ រៀបចំប្រព័ន្ធខ្យល់-លាងសម្អាតអាង

### *៣.១.៤. <u>ការរៀបចំប្រព័ន្ធខ្យល់÷</u>*

ប្រព័ន្ធខ្យល់ត្រូវរៀបចំ និងបើកដំណើរការក្នុងពេលកែទឹកឬយ៉ាងហោចណាស់ពី ៣-៤ថ្ងៃមុនពេលដាក់កូនត្រីដើម្បីជំរុញប្រសិទ្ធភាពនៃការកែគុណភាពទឹក និងបង្កើតអុកស៊ីសែនក្នុងអាងយ៉ាងតិចមួយម៉ោងដោយបើកកម្លាំងម៉ូទ័រខ្យល់ពី ២៥-៣៥លីត្រ/នាទី ។









### ៣.១.៥.ការគណនាមាឌអាង និងបរិមាណទឹកក្នុងអាង÷




**-គណនាមាឌអាង÷**

រូបមន្តមាឌអាង = $\pi r^2$h

$\pi = 3.14$ r = ($\frac{d}{2}$)

មាឌអាង =3.14x($\frac{3}{2}$)$^2$ x 1.2

=3.14x (1.5)$^2$x 1.2

=3.14x 2.25 x1.2

=<u>8.47m$^3$</u>

**-គណនាមាឌទឹក÷**

រូបមន្តមាឌទឹក

$\pi = 3.14$ r = ($\frac{d}{2}$)

មាឌទឹក =3.14x ($\frac{3}{2}$)$^2$ x 1

=3.14x (1,5)$^2$x 1

=3.14x 2.25 x1

=<u>7.06m$^3$</u>

***សម្គាល់÷*** *π គឺជាផលធៀបរវាងបរិមាត្ររង្វង់មួយទៅនឹងអង្កត់ផ្ចិតរបស់វា ដោយតាងឱ្យតម្លៃថេរជានិច្ចស្មើនឹង 3.14 នៅក្នុងផ្នែកគណិតវិទ្យា និងវិទ្យាសាស្ត្រ។*

### ៣.១.៦.ការបញ្ចូលទឹក និងកែគុណភាពទឹកមុនពេលដាក់កូនត្រី ÷

ការបញ្ចូលទឹកលើកដំបូងទៅក្នុងអាងគួរមានជម្រៅ ០.២-០.៣ម៉ និងដាក់អំបិលក្រួសចំនួន ១គ.ក ទៅក្នុងអាងដើម្បីកែគុណភាពទឹក និងសម្លាប់មេរោគមួយចំនួននៅក្នុងទឹក។ រយៈពេល៤៨ម៉ោងក្រោយ ត្រូវបញ្ចូលទឹកដល់កម្រិត ១ម៉ែត្ររួចទើបដាក់កូនត្រីពូជទៅក្នុងអាងចិញ្ចឹមបាន។

**ការបង្កើតទឹកល្បាយអតិសុខុមប្រាណនៃកាបូនសរីរាង្គ (Fermented of Carbon Organic, FCO)**

| លរ | វត្ថុធាតុដើម | សម្រាប់ទឹក១០០លីត្រ | វិធីអនុវត្តន៍ |
|---|---|---|---|
| ១ | អំបិលក្រួស | ៤០០ក្រាម | លាយវត្ថុធាតុដើមទាំងបីក្នុងធុងទឹកចំណុះ ១០០លីត្រ និងបើកប្រព័ន្ធខ្យល់ រយៈពេល ៣២ម៉ោងក្រោយអាចយកទៅប្រើបាន។ |
| ២ | ស្កររង្វ | ១០០ក្រាម | |
| ៣ | ប្រូបាយអូទិក (Probiotic) | ១០ក្រាម(១ស្លាបព្រាបាយ) | |

***សម្គាល់÷*** *រូបមន្តបង្កើត FCO ខាងលើជាបទពិសោធន៍ជាក់ស្តែងរបស់កសិដ្ឋានមហាលាភ (YouTube Mahaleap action)*



អំបិលក្រួស



ស្កររង្វ




ប្រូបាយអូទិក



ទឹកល្បាយ FCO

### ៣.២.ការជ្រើសរើសកូនត្រីពូជ÷

ចំណុចសំខាន់ៗក្នុងការជ្រើសរើសកូនត្រីពូជល្អមានដូចខាងក្រោម÷

- មានទម្ងន់ចន្លោះពី ៥-១០ក្រាម/ក្បាល

- មានទំហំប៉ុនៗគ្នា ឬប្រហាក់ប្រហែលគ្នា
- មានសុខភាពល្អ ÷ មានសាច់ មាំមួន ពណ៌សម្បុរស្រស់ថ្លា រហ័សរហួន
- គ្មានរបួសស្នាមឬដំបៅលើដងខ្លួន មានរូបរាងស្អាត គ្មានដុំពកឬប៉ោង
- គ្មានផ្នែកណាមួយខុសប្រក្រតី
- ផលិតក្នុងស្ថានីយដែលមានការកត់ត្រាច្បាស់លាស់ មានកេរ្តិ៍ឈ្មោះល្អ និងរៀបចំស្អាត។

### ៣.៣. ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹម÷

ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមជាកត្តាសំខាន់ដែលកំណត់នូវការលូតលាស់ ធំធាត់ អត្រារស់របស់ត្រី ហើយក៏ជាកត្តាបង្កឱ្យមានកម្រិតកខ្វក់នៃទឹកដែលជាបុព្វហេតុចម្បងបង្កឱ្យត្រីមានជំងឺ។ ដូចនេះ អ្នកចិញ្ចឹម គួរដាក់កូនត្រីចិញ្ចឹមនូវកម្រិតដង់ស៊ីតេសមស្របមួយតាមបច្ចេកទេស។

យោងតាមឯកសារមួយចំនួនបានបង្ហាញថា ការចិញ្ចឹមត្រីទីឡាព្យាតាមប្រព័ន្ធ Biofloc សមត្ថភាពផ្ទុករបស់អាងគឺចន្លោះពី ២០-៤០គ.ក/ម៉$^{៣}$ឬអាចដាក់កូនត្រីចិញ្ចឹមចន្លោះពី ៤០-៨០ក្បាល/ម៉$^{៣}$។ ទន្ទឹមនេះ មានឯកសារបច្ចេកទេសមួយចំនួនទៀតបញ្ជាក់ថាការដាក់ត្រីចិញ្ចឹមអាចចន្លោះពី ២០០-៤០០ក្បាល/ម៉$^{៣}$។ ជាក់ស្តែងសម្រាប់ការចិញ្ចឹមត្រីទីឡាព្យាតាមប្រព័ន្ធ Biofloc នៅខេត្តបន្ទាយមានជ័យ កសិករបានដាក់ត្រីចិញ្ចឹមចំនួន ២១២ក្បាល/ម៉$^{៣}$ ស្មើនឹង ១,៥០០ក្បាលក្នុងអាងមានចំណុះទឹក ៧ម៉ែត្រគីប ។




### ៣.៤. ការលែងកូនត្រីពូជ÷

មុនលែងកូនត្រីទៅក្នុងអាងត្រូវដាក់ថង់ត្រីត្រាំក្នុងអាងរយៈពេលពី ១០-២០នាទីធ្វើឱ្យសីតុណ្ហភាពខាងក្រៅនិងក្នុងថង់ប្រហាក់ប្រហែលគ្នានិងបន្ថយការនឿយហត់របស់ត្រី។ បន្ទាប់មកស្រាយមាត់ថង់ថ្មមៗ និងបាចទឹកពីខាងក្រៅចូលទៅក្នុងថង់បន្តិចម្តងៗរួចឱ្យកូនត្រីហែលចេញតាមសម្រួល។ មិនត្រូវចាក់កូនត្រីចូលអាងភ្លាមៗនោះទេ ពីព្រោះទឹកក្នុងអាងនិងក្នុងថង់មានសីតុណ្ហភាពខុសគ្នា ដែលកូនត្រីមិនអាចធន់នឹងការប្រែប្រួលសីតុណ្ហភាពយ៉ាងឆាប់រហ័សនោះទេ អាចធ្វើឱ្យត្រីខ្សោយ ឬងាប់បាន។

### ៣.៥. ការផ្តល់ចំណី÷

អ្នកចិញ្ចឹមគួរផ្តល់ចំណីបន្ទាប់ពីលែងកូនត្រីចូលអាងរយៈពេលពី ២-៣ម៉ោង នូវបរិមាណចំណីតិចតួច។ ថ្ងៃបន្ទាប់អាចចាប់ផ្តើមដាក់ចំណីឱ្យកូនត្រីតាមបរិមាណស្របតាមបច្ចេកទេស ២-៣ដង/ថ្ងៃ នៅពេលព្រឹកម៉ោង ៨ ថ្ងៃត្រង់ម៉ោង ១១-១២ និងរសៀលពីម៉ោង៤-៥ល្ងាច។

### *តារាងបច្ចេកទេសនៃការផ្តល់ចំណីត្រីប្រចាំថ្ងៃ (ចំណីគ្រាប់)÷*

| ទម្ងន់កូនត្រីមធ្យម ក្នុង១ក្បាល (ក្រាម) | % ចំណីនៃទម្ងន់ខ្លួនត្រី | ចំនួនដងត្រូវផ្តល់/ថ្ងៃ | % កម្រិតប្រូតេអ៊ីនក្នុងចំណី | ទំហំចំណី (លី) |
|---|---|---|---|---|
| ៦-២០ | ៦ | ៣ | ៣២ | ១ |
| ២១-៥០ | ៥ | ២ | ៣០ | ១.៥ |
| ៥១-១០០ | ៤ | ២ | ២៨ | ២ |
| ១០១-៣០០ | ៣.៥-៣ | ២ | ២៨ | ៣-៤ |
| ៣០១-៤០០ | ២.៥ | ២ | ២៤ | ៤ |
| ៤០១-៦០០ | ២-១.៥ | ២ | ២៤ | ៤ |
| ៦០០ក្រាមឡើង | ១ | ២ | ២០ | ៤ |

***សម្គាល់***÷ *តារាងខាងលើនេះយោងតាម* https://agrifarming.in/biofloc-fish-feeding-chart-per-body-weight

*-ភាគរយចំណីនៃទម្ងន់ដងខ្លួនត្រីអាចប្រែប្រួលអាស្រ័យលើកម្រិតបរិមាណប្លង់តុងដែលកើតមាននៅក្នុងអាង និងការផ្តល់ចំណីផ្សំបន្ថែមរបស់អ្នកចិញ្ចឹម។*

**រូបមន្តគណនាចំណីត្រូវផ្តល់ប្រចាំថ្ងៃ÷**

$$\text{បរិមាណចំណីត្រូវផ្តល់ក្នុង១ថ្ងៃ} = \frac{\text{ទំងន់ត្រីសរុប} \times \text{\% ចំណីនៃទម្ងន់ខ្លួនត្រី}}{\text{១០០}}$$

ទម្ងន់ត្រីសរុប = ទម្ងន់មធ្យមកូនត្រីក្នុង១ក្បាល x ចំនួនត្រីសរុបក្នុងស្រះ

ក្រៅពីចំណីសម្រេចពីរោងចក្រកសិករអាចផ្តល់ចំណីផ្សំបន្ថែមមានដូចជា ចកអាសូឡា សំណល់ផ្ទះបាយ ត្រីនុយ គ្រឿងក្នុងមាន់-ទា និងសំណល់ពីសត្តឃាតដ្ឋាន ដើម្បីចូលរួមកាត់បន្ថយថ្លៃដើមផលិតកម្ម។

របៀបធ្វើចំណីពីសំណល់សត្តឃាតដ្ឋាន និងគ្រឿងក្នុងមាន់-ទា សម្រាប់ដាក់ឱ្យត្រីស៊ី÷

-ជំហានទី១÷ លាងសម្អាតកាកសំណល់ផ្សេងៗចេញ

-ជំហានទី២÷ ស្ងោរឱ្យឆ្អិន ដើម្បីសម្លាប់មេរោគ កាត់បន្ថយភាពស្វិត និងឆ្អាប

-ជំហានទី៣÷ កិនឱ្យល្អិតតូចៗ សមស្របនឹងទំហំកូនត្រីអាចស៊ីបាន

-ជំហានទី៤÷ សម្អាតកម្ទេចកម្ទីដែលនៅសេសសល់ ចម្រោះឱ្យអស់ទឹក និងដាក់ឱ្យត្រីស៊ី





## ៣.៦. ការគ្រប់គ្រង និងថែទាំ÷

**-ការគ្រប់គ្រងគុណភាពទឹក÷** គុណភាពទឹកសមស្របតាមលក្ខខណ្ឌ គឺបង្កើតបានប្លង់តុងដែលជាចំណីត្រីមានប្រូតេអ៊ីនខ្ពស់ និងបង្ការជំងឺឬគ្រោះថ្នាក់ជាយថាហេតុលើដំណើរការចិញ្ចឹម។ អ្នកចិញ្ចឹមត្រូវពិនិត្យតាមដានគុណភាពទឹក១ដង/សប្តាហ៍ ទៅតាមតារាងខាងក្រោម÷

*តារាងប៉ារ៉ាម៉ែត្រគុណភាពទឹក*÷

| លរ | សមាសធាតុនៃគុណភាពទឹក | កម្រិតសមស្រប |
|---|---|---|
| ១ | សីតុណ្ហភាព | ២៨-៣០ អង្សាសេ |
| ២ | pH | ៧-៨ |
| ៣ | អុកស៊ីសែនក្នុងទឹក (DO) | >៤ មីលីក្រាម/លីត្រទឹក |
| ៤ | នីត្រាត ($NO_3$) | ១០-១២ ppm |
| ៥ | នីទ្រីត ($NO_2$) | 0.0៥-0.១ ppm |
| ៦ | អាម៉ូញាក់ ($NH_3$) | 0.0១-0.0៥ ppm |
| ៧ | អាល់កាឡាំង (Alkalinity) | ១៥៥-១៧0 ppm |
| ៨ | ភាពរឹងនៃទឹក (Hardness) | ៦១0-៦៥0 ppm |
| ៩ | TAN * | <0.៥ មីលីក្រាម/លីត្រទឹក |
| ១0 | TSS ** | ៦១0-៧៦0 មីលីក្រាម/លីត្រទឹក |
| ១១ | TDS *** | <១,000 មីលីក្រាម/លីត្រទឹក |

**ឧបករណ៍វាស់ អុកស៊ីសែន និង ($NO_2$) នៅក្នុងទឹក**




**ក្រដាស់ពណ៌ វាស់កំហាប់ pH ទឹក**



*-កំហាប់pH ចន្លោះពី ៧-៨ ជាកម្រិតសមស្រប*

**TAN (Total Ammonia Nitrogen) គឺជាបរិមាណសរុបនៃអាម៉ូញាក់ និងអាសូតនៅក្នុងទឹក។ បើសិនជា TAN ឡើងខ្ពស់នាំឱ្យត្រីងាប់។Mahaleap Action* https://www.youtube.com/@mahaleapac/videos

***TSS (Total Suspended Solids) គឺភាគល្អិតនៅក្នុងទឹកដែលមិនត្រូវបានរំលាយ អាចត្រងជាប់ដោយប្រព័ន្ធចម្រោះទឹក មានទំហំតូចលើសពី ២មីក្រុង។*

**** TDS (Total Dissolved Solids) គឺជាភាគល្អិតដែលបានរំលាយនៅក្នុងទឹក មានទំហំតូចជាង ២មីក្រុង ធាតុទាំងនោះអាចជា អំបិល សារធាតុរ៉ែ លោហធាតុ កាល់ស្យូម និងសារធាតុផ្សេងៗរួមទាំងសរីរាង្គ និងអសរីរាង្គ។*
http://www.sewagetreatmentplants.in/what-is-total-suspended-solids-tss-in-water/

**-ការថែទាំគុណភាពទឹក÷**

ដើម្បីរក្សាបាននូវគុណភាពទឹកឱ្យមានសារធាតុចិញ្ចឹមគ្រប់គ្រាន់សម្រាប់ការលូតលាស់របស់ត្រី កសិករត្រូវដាក់បញ្ចូលទឹក FCO ចំនួន ០.៥លីត្រ រាល់២ថ្ងៃម្តងទៅក្នុងអាងចិញ្ចឹមត្រី និងប្តូរទឹកពី ២០ ទៅ ៣០% ក្នុងមួយសប្តាហ៍អាស្រ័យលើកម្រិតប្លុក(Floc)នៃទឹក ដោយប្រើឧបករណ៍អ៊ិនហុស្សខន (Inhoff Cone) ដែលកម្រិតប្លុកសមស្របចន្លោះពី ២០-៣០ ml/L។




**៣.៧.ការបង្ការ និងការព្យាបាលជំងឺត្រី÷**

ការចិញ្ចឹមត្រីតាមប្រព័ន្ធ Biofloc ត្រីកម្រកើតមានជំងឺខ្លាំងណាស់ ប្រសិនបើកសិករមានការគ្រប់គ្រងគុណភាពទឹកបានត្រឹមត្រូវ ដង់ស៊ីតេដាក់កូនត្រីចិញ្ចឹមសមស្របនិងមានប្រព័ន្ធខ្យល់បង្កើតកម្រិតអុកស៊ីសែនគ្រប់គ្រាន់។ មានជំងឺតិចតួចប៉ុណ្ណោះកើតមានលើត្រីទីឡាព្យាក្រហម ដែលបង្កឡើងពីពពួកបាក់តេរី និងប៉ារ៉ាស៊ីត ក្នុងនោះរួមមាន÷

**ក.ជំងឺហើមភ្នែក÷** បង្កឡើងពីបាក់តេរីឈ្មោះ Streptococcus ដែលរីករាលដាលខ្លាំងនៅពេលសីតុណ្ហភាពទឹកចន្លោះពី ២០-៣០អង្សាសេ។

***<u>វិធីព្យាបាល</u>÷***

-ផ្លាស់ប្តូរទឹក ៤០-៥០% បន្ទាប់មកបង្កើនកម្រិតខ្យល់ បង្កើនកម្រិតអុកស៊ីសែនក្នុងទឹកអាង។

-លាយថ្នាំ Beta Glucan និងប្រភេទវីតាមីន ជាមួយចំណីឱ្យត្រីស៊ីរយៈពេលពី ៥-៧ថ្ងៃ។



### ខ. ជំងឺបង្កមកពីប៉ារ៉ាស៊ីត÷

***ការបង្ការ÷*** អ្នកចិញ្ចឹមគួរប្រើថ្នាំទម្លាក់ព្រូនឬសម្លាប់ប្រភេទសត្វល្អិតដែលតោងជាប់លើដងខ្លួន និងក្នុងខ្លួនត្រីជាប្រចាំ ដើម្បីរក្សាបានការលូតលាស់ធំធាត់បានសមស្របតាមផែនការ ដោយប្រើប្រាស់មួយខែម្តង នូវប្រភេទថ្នាំដែលមានធាតុសកម្មដូចជា Albendazole Pipeprazin Prazinquantel និង Excipient qs ។

***វិធីព្យាបាល÷***

-ផ្លាស់ប្តូរទឹក ៤០-៥០% បន្ទាប់មកបង្កើនកម្រិតខ្យល់ បង្កើនកម្រិតអុកស៊ីសែនក្នុងទឹកអាង។

-ប្រើហ្វកម៉ូល Formol កម្រិត ២៥-៣0ml/m$^3$ រយៈពេលវែង ឬប្រើ១០០-១៥0ml/m$^3$ រយៈពេល ១៥-៣០នាទី។ ឬ

-ប្រើប៉ូតាស្យូមពែរម៉ង់កាណាត (KMnO4) ២-៤mg/L ទឹក ដាក់២ដង/សប្តាហ៍។ ឬ

-ប្រើទង់ដែងស៊ុលហ្វាត (CuSO4) ចំនួន 0,៥ mg/L ទឹក រយៈពេល១-២នាទី ក្នុងអាងត្រី













### ៣.៨. ការប្រមូលផល÷

ចិញ្ចឹមរយៈពេល៥ខែ ត្រីមានទំហំចន្លោះពី ០.៤-០.៦គីឡូក្រាម/ក្បាល។ មុនពេលប្រមូលផល ១-២ថ្ងៃ ត្រូវផ្តាច់ឬកាត់បន្ថយផ្តល់ចំណីមកនៅត្រឹមកម្រិតតិចតួចបំផុត ដើម្បីជៀសវាងបញ្ហាត្រីហល់ពោះ ខ្ជាក់ចំណីចោល និងអាចបង្កឱ្យត្រីឆាប់ងាប់។ កសិករត្រូវប្រមូលផលឱ្យបានលឿនតាមដែលអាចធ្វើទៅបានតាមភាពជាក់ស្តែង កុំឱ្យប៉ះពាល់ដល់សាច់ត្រី ដោយអាស្រ័យលើទម្ងន់ត្រី និងតម្លៃទីផ្សារ។ ក្រោយប្រមូលផលរួច ត្រូវជ្រើសរើសពេលវេលាសមស្របក្នុងការរៀបចំអាងឱ្យបានស្អាតដូចមុន ដើម្បីចិញ្ចឹមបន្តនៅវគ្គក្រោយ។





## ៤-គម្រោងចំណាយលើការចិញ្ចឹមត្រីទីឡាព្យាតាមប្រព័ន្ធបាយអូហ្វក៖

**៤-១- គម្រោងចិញ្ចឹម** (បទពិសោធន៍របស់កសិករនៅក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)

| | | |
|---|---|---|
| - ចិញ្ចឹមតាមប្រព័ន្ធ Biofloc | ÷ | អាងមូលចំនួន ៣ មានមុខកាត់ ៣ម៉ កម្ពស់អាង ១.២ម៉ និង ជម្រៅទឹក ១ម៉ (មានចំណុះទឹក ៧.០៦ម៉$^{៣}$)។ |
| - ចំនួនកូនត្រីពូជ/វគ្គ | ÷ | ៤,៥០០កូន (១,៥០០កូន/អាង) |
| - ប្រភពកូនត្រីពូជ | ÷ | ទិញពីកសិដ្ឋានផលិតកូនត្រីតម្លៃ ១០០៛/ក្បាល |
| - ចំនួនវគ្គចិញ្ចឹម/ឆ្នាំ | ÷ | ២វគ្គ/ឆ្នាំ |
| - រយៈពេលចិញ្ចឹម | ÷ | ៤.៥-៥ខែ/វគ្គ |
| - ចំណីផ្តល់ឱ្យត្រីស៊ី | ÷ | ចំណីគ្រាប់ក្រុមហ៊ុន មានកម្រិតប្រូតេអ៊ីនពី ២៨-៤០% និង ចំណីបន្ថែម (គ្រឿងក្នុងមាន់-ទា និងចកអាស្វូឡា) ។ |
| - អត្រាបាត់បង់ | ÷ | ១០-២០% (អាស្រ័យលើសុខភាពកូនត្រីពូជ និងការថែទាំ) |
| - សមាមាត្រចំណី (FCR) | ÷ | ចន្លោះពី ១-១.២ |
| - ទិន្នផល | ÷ | ជាមធ្យម ១,៩១៣ គ.ក/វគ្គ |
| - ទីផ្សារ | ÷ | លក់ឱ្យឈ្មួញបោះដុំ និងលក់រាយនៅផ្សារក្រុងប៉ោយប៉ែត |
| - តម្លៃទីផ្សារ | ÷ | លក់ឱ្យឈ្មួញបោះដុំចន្លោះពី ៦,៥០០-៧,៥០០៛/គ.ក និងលក់ឱ្យអ្នកលក់រាយក្នុងផ្សារតម្លៃចន្លោះពី ៨,០០០ - ១០,០០០៛/គ.ក ។ |
| - តម្រូវការទុន | ÷ | ចាប់ផ្តើមអាជីវកម្មដំបូង ដោយរៀបចំអាងចិញ្ចឹម ប្រព័ន្ធខ្យល់ បង្កើតអុកស៊ីសែន ប្រព័ន្ធបញ្ចេញបញ្ចូលទឹក និងបំពាក់សម្ភារៈ (មិនរាប់បញ្ចូលថ្លៃដី) ត្រូវចំណាយដើមទុនប្រមាណ **12,989,000 រៀល** ក្នុងនោះ÷ |

| ទុនវិនិយោគសម្រាប់ធ្វើអាង រៀបប្រព័ន្ធខ្យល់-ទឹក និងបំពាក់សម្ភារៈ (រៀល) | ទុនសម្រាប់ដំណើរការចិញ្ចឹមត្រីទីឡាព្យាក្រហម (រៀល) | ទឹកប្រាក់សរុប (រៀល) |
|---|---|---|
| **4,750,000** | **8,239,000** | **12,989,000** |

**៤-២-ចំណាយលម្អិតលើការចាប់ផ្តើមអាជីវកម្មដំបូង÷**

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|
| **ចំណាយសរុប ក+ខ** | | | | | **12,989,000** |
| **ក-ការចំណាយប្រែប្រួល** | | | | | **8,239,000** |
| 1 | កូនត្រីពូជ | ក្បាល | 4,500 | 100 | 450,000 |

| | | | | | |
|---|---|---|---|---|---|
| 2 | ចំណីសម្រេច(ប្រូតេអ៊ីន ៣០-៤០%) | គ.ក | 2,104 | 3,000 | 6,312,000 |
| 3 | ចំណីផ្សំ(គ្រឿងក្នុងសត្វ និងចកអាសូឡា) | គ.ក | 420 | 400 | 168,000 |
| 4 | ថ្នាំកែទឹកប្រូបាយអូទិក (Probiotic) | ដប | 1 | 40,000 | 40,000 |
| 5 | អំបិលគ្រួស | គ.ក | 25 | 1,400 | 35,000 |
| 6 | ស្កររង្វូ | គ.ក | 30 | 1,500 | 45,000 |
| 7 | កម្លាំងពលកម្ម/វគ្គ | ខែ | 5 | 200,000 | 1,000,000 |
| 8 | ថ្លៃអគ្គិសនី/វគ្គ | គ.វ | 270 | 700 | 189,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | **4,750,000** |
| 1 | កៅស៊ូតង់មូលមុខកាត់៣ម | អាង | 3 | 280,000 | 840,000 |
| 2 | ស័ង្កសីលាត 4c កម្ពស់ ១.២ម | ម៉ែត្រ | 10 | 40,000 | 400,000 |
| 3 | ដែកថ្នាំងអំពៅ ១២លី | ម៉ែត្រ | 108 | 8,000 | 864,000 |
| 4 | ដែកមូលតាន់ ៦លី | គ.ក | 30 | 4,000 | 120,000 |
| 5 | ទុយោ៦0mm កែង ឆ្នុក និងវ៉ាន | អាង | 3 | 60,000 | 180,000 |
| 6 | ម៉ូទ័រខ្យល់ | គ្រឿង | 1 | 480,000 | 480,000 |
| 7 | វ៉ាន់បិទបើកខ្យល់ | វ៉ាន | 3 | 2,000 | 6,000 |
| 8 | ដុំថ្មពពុះខ្យល់ | ដុំ | 15 | 4,000 | 60,000 |
| 9 | បំពង់ខ្យល់ជ័រទន់ | ម៉ែត្រ | 50 | 2,000 | 100,000 |
| 10 | ធុងជ័រចំណុះ ៥០លីត្រ (ធ្វើ FCO) | ធុង | 1 | 120,000 | 120,000 |
| 11 | ម៉ូទ័របូមទឹក | គ្រឿង | 1 | 200,000 | 200,000 |
| 12 | ទុយោបូមទឹក | ដើម | 20 | 16,000 | 320,000 |
| 13 | អាងតង់ដាំចកអាសូឡា(២ម x ៣ម) | អាង | 1 | 80,000 | 80,000 |
| 14 | អ៊ីនហុស្សខន (Inhoff Cone) | ឈុត | 1 | 240,000 | 240,000 |
| 15 | ឧបករណ៍វាស់គុណភាពទឹក | ឈុត | 4 | 60,000 | 240,000 |
| 16 | ជញ្ជីងថ្លឹងអេឡិចត្រូនិច | គ្រឿង | 1 | 100,000 | 100,000 |
| 17 | ខ្សែភ្លើង | ម៉ែត្រ | 100 | 4,000 | 400,000 |

### ៤-៣-ការវិភាគសេដ្ឋកិច្ចក្នុងការចិញ្ចឹម១វគ្គ÷

ការវិភាគសេដ្ឋកិច្ចសម្រាប់ការចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ Biofloc នៅក្នុងអាងចិញ្ចឹមចំនួន៣ មានមុខកាត់៣ម៉ ដោយដាក់កូនត្រីសរុបចំនួន **៤,៥០០ក្បាល** (១,៥០០ក្បាល/អាង)ចិញ្ចឹមរយៈពេល ៤.៥-៥ ខែ (ក្នុង១វគ្គ) ក្នុងអត្រាបាត់បង់កូនត្រី ១៥% និងការកាត់រំលស់ឧបករណ៍-សម្ភារៈ ÷

| ចំណាយសរុប (រៀល) | ចំណូលសរុប (រៀល) | ចំណេញសរុប (រៀល) |
|---|---|---|
| **8,821,400** | **17,217,000** | **8,395,600** |

## -តារាងចំណូល-ចំណាយលម្អិត÷

| លរ | មុខចំណាយ | ឯកតា | ចំនួន | តម្លៃរាយ (រៀល) | ចំនួនវដ្ត វិលស់ | តម្លៃសរុប (រៀល) |
|---|---|---|---|---|---|---|
| **ចំណូលពីការលក់** | | | | | | |
| 1 | ចំណូលពីការលក់ | គ.ក | 1,913 | 9,000 | | **17,217,000** |
| **ចំណាយសរុប ក+ខ** | | | | | | **8,821,400** |
| **ក-ការចំណាយប្រែប្រួល** | | | | | | **8,239,000** |
| 1 | កូនត្រីពូជ | ក្បាល | 4,500 | 100 | | 450,000 |
| 2 | ចំណីសម្រេច(ប្រូតេអ៊ីន ៣0-៤0%) | គ.ក | 2,104 | 3,000 | | 6,312,000 |
| 3 | ចំណីផ្សំ(គ្រឿងក្នុងសត្វ និងចកអាស្វូឡា) | គ.ក | 420 | 400 | | 168,000 |
| 4 | ថ្នាំកែទឹកប្រូបាយអូទិក (Probiotic)/វគ្គ | ដប | 1 | 40,000 | | 40,000 |
| 5 | អំបិលគ្រួស | គ.ក | 25 | 1,400 | | 35,000 |
| 6 | ស្កររង្វ | គ.ក | 30 | 1,500 | | 45,000 |
| 7 | កម្លាំងពលកម្ម/វគ្គចិញ្ចឹម | ខែ | 5 | 200,000 | | 1,000,000 |
| 8 | ថ្លៃអគ្គិសនី/វគ្គចិញ្ចឹម | គ.វ | 270 | 700 | | 189,000 |
| **ខ-ចំណាយមិនប្រែប្រួល/ថេរ** | | | | | | **582,400** |
| 1 | អាងចិញ្ចឹមមូលមុខកាត់៣ម (កៅស៊ូតង់) | អាង | 3 | 280,000 | 10 | 84,000 |
| 2 | ស័ង្កសីលាត 4c កម្ពស់ ១.២ម | ម៉ែត្រ | 10 | 40,000 | 10 | 40,000 |
| 3 | ដែកថ្នាំងអំពៅ ១២លី | ម៉ែត្រ | 108 | 8,000 | 10 | 86,400 |
| 4 | ដែកមូលតាន់ ៦លី | គ.ក | 30 | 4,000 | 10 | 12,000 |
| 5 | ទុយោ៦0 mm កែង ឆ្នុក និងវ៉ាន | អាង | 3 | 60,000 | 10 | 18,000 |
| 6 | ម៉ូទ័រខ្យល់ | គ្រឿង | 1 | 480,000 | 10 | 48,000 |
| 7 | វ៉ានបិទបើកខ្យល់ | វ៉ាន | 1 | 2,000 | 6 | 333 |
| 8 | ដុំថ្មពពុះខ្យល់ | ដុំ | 20 | 4,000 | 10 | 8,000 |
| 9 | បំពង់ខ្យល់ជ័រ | ម៉ែត្រ | 50 | 2,000 | 6 | 16,667 |
| 10 | ធុងជ័រចំណុះ ៥0លីត្រ (ធ្វើ FCO) | ធុង | 1 | 120,000 | 6 | 20,000 |
| 11 | ម៉ូទ័របូមទឹក | គ្រឿង | 1 | 200,000 | 6 | 33,333 |
| 12 | ទុយោបូមទឹក | ដើម | 20 | 16,000 | 6 | 53,333 |
| 13 | អាងដាំចកអាស្វូឡា (២ម x ៣ម) | អាង | 1 | 80,000 | 6 | 13,333 |
| 14 | អ៊ីនហុស្សខន (Inhoff Cone) | ឈុត | 1 | 240,000 | 10 | 24,000 |

| | | | | | | |
|---|---|---|---|---|---|---|
| 15 | ឧបករណ៍វាស់គុណភាពទឹក | ឈុត | 4 | 60,000 | 4 | 60,000 |
| 16 | ជញ្ជីងថ្លឹងអេឡិចត្រូនិច | គ្រឿង | 1 | 100,000 | 4 | 25,000 |
| 17 | ខ្សែភ្លើង | ម៉ែត្រ | 100 | 4,000 | 10 | 40,000 |
| **ចំណេញសរុប** | | | | | | **8,395,600** |
| ចំណាយថ្លៃដើមក្នុងការចិញ្ចឹមត្រីក្នុង១ គ.ក | | | | | | **4,611** |
| ចំណេញពីការផលិតត្រីសាច់ ១ គ.ក | | | | | | **4,389** |

## ៤-៤-ការវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់÷

តាមរយៈបទពិសោធន៍របស់កសិករដែលក្រុមការងារបានសិក្សាផ្ទាល់ ការចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ Biofloc មានអត្រាបាត់បង់ចន្លោះពី ១០-២០% អាស្រ័យលើការគ្រប់គ្រងគុណភាពទឹក និងការផ្តល់ចំណី។ ដោយឡែកទំហំត្រីពេលប្រមូលផលមិនស្មើគ្នា ក៏អាចប៉ះពាល់ដល់ទិន្នផលសរុបផងដែរ។

**តារាងវិភាគលទ្ធផលដោយផ្អែកលើតម្លៃលក់មានដូចខាងក្រោម÷**

| ទិន្នផលទទួលបាន(គ.ក) | តម្លៃលក់ចេញ (រៀល) | ចំណូលសរុប (រៀល) | ចំណាយសរុប (រៀល) | ចំណេញ (រៀល) | កំណត់សម្គាល់អំពីទិន្នផល |
|---|---|---|---|---|---|
| 2,025 | 7,000 | 14,175,000 | 8,821,400 | 5,353,600 | កូនត្រីមានអត្រាបាត់បង់ ១០% និងមានទំហំមធ្យម ៥០០ក្រាម/ក្បាល |
| | 8,000 | 16,200,000 | 8,821,400 | 7,378,600 | |
| | 9,000 | 18,225,000 | 8,821,400 | 9,403,600 | |
| | 10,000 | 20,250,000 | 8,821,400 | 11,428,600 | |
| 1,913 | 7,000 | 13,391,000 | 8,821,400 | 4,569,600 | កូនត្រីមានអត្រាបាត់បង់ ១៥% និងមានទំហំមធ្យម ៥០០ក្រាម/ក្បាល |
| | 8,000 | 15,304,000 | 8,821,400 | 6,482,600 | |
| | 9,000 | 17,217,000 | 8,821,400 | 8,395,600 | |
| | 10,000 | 19,130,000 | 8,821,400 | 10,308,600 | |
| 1,800 | 7,000 | 12,600,000 | 8,821,400 | 3,778,600 | កូនត្រីមានអត្រាបាត់បង់ ២០% និងមានទំហំមធ្យម ៥០០ក្រាម/ក្បាល |
| | 8,000 | 14,400,000 | 8,821,400 | 5,578,600 | |
| | 9,000 | 16,200,000 | 8,821,400 | 7,378,600 | |
| | 10,000 | 18,000,000 | 8,821,400 | 9,178,600 | |

**សម្គាល់÷**ក្នុងករណីកូនត្រីពូជមានសុខភាពមិនល្អ ការគ្រប់គ្រងនិងការថែទាំមិនបានត្រឹមត្រូវ ឬមានបញ្ហាដាច់ចរន្តអគ្គិសនីជាយថាហេតុណាមួយកើតឡើងអាចនាំឱ្យអត្រាបាត់បង់ឡើងដល់២០% ឬអាចច្រើនជាងនេះដែលប៉ះពាល់ដល់ទិន្នផលត្រីសរុប និងផលចំណេញរបស់កសិករ។ ដោយឡែកតម្លៃត្រីនៅលើទីផ្សារក៏មានការប្រែប្រួលមិនទៀងទាត់ផងដែរ។ កសិករមានជម្រើសពីរក្នុងការលក់ត្រី គឺលក់ទៅឱ្យឈ្មួញបោះដុំក្នុងតម្លៃចន្លោះពី ៦,៥០០-៧,៥០០៛/គ.ក និងលក់រាយឱ្យឈ្មួញលក់រាយនៅក្នុងផ្សារដោយ តម្លៃចន្លោះពី ៨,០០០-១០,០០០៛/គ.ក។

### ៤-៥-ការវិភាគលើខ្សែច្រវាក់តម្លៃ÷

-ជម្រើសទី១÷

**កសិករ** ÷ ករណីលក់ទៅឈ្មួញកណ្តាលបោះដុំបានតម្លៃមធ្យម ៧,០០០៛/គ.ក តម្លៃថ្លៃដើមផលិត ៤,៦១១៛/គ.ក កសិករអាចចំណេញបាន ២,៣៨៩៛/គ.ក ។

↓

**ឈ្មួញកណ្តាល**÷ លក់ទៅអ្នកលក់រាយក្នុងផ្សារបានតម្លៃ ៩,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ ៥០០៛/គ.ក អាចចំណេញបាន ១,៥០០៛/គ.ក ។

↓

**អ្នកលក់រាយ** ÷ លក់បានតម្លៃ ១២,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ និងថែរក្សា ៥០០៛/គ.ក អាចចំណេញបាន ២,៥០០៛/គ.ក ។

-ជម្រើសទី២÷

**កសិករ**÷ លក់ទៅឱ្យអ្នកលក់រាយក្នុងផ្សារបានតម្លៃ ៩,០០០៛/គ.ក កាត់លើថ្លៃដើមផលិត ៤,៦១១៛/គ.ក កសិករអាចចំណេញបាន ៤,៣៨៩៛/គ.ក ។

↓

**អ្នកលក់រាយ** ÷ លក់បានតម្លៃ ១២,០០០៛/គ.ក កាត់លើថ្លៃដឹកជញ្ជូន លើកដាក់ និងថែរក្សា ៥០០៛/គ.ក អាចចំណេញបាន ២,៥០០៛/គ.ក ។

## ៥-ហានិភ័យ និងបញ្ហាប្រឈម

តាមការសិក្សាផ្ទាល់នៅកសិដ្ឋានចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ Biofloc កសិករដែលមានបំណងចិញ្ចឹមត្រូវស្វែងយល់ និងរកវិធីគ្រប់គ្រងនូវហានិភ័យ និងបញ្ហាប្រឈមចម្បងៗមួយចំនួនទៅលើអាជីវកម្មរួមមានដូចខាងក្រោម÷

❖ **ហានិភ័យផលិតកម្ម÷**

-ប្រភពទឹកស្អាតមិនគ្រប់គ្រាន់÷ ទោះបីជាការចិញ្ចឹមត្រីតាមប្រព័ន្ធ Biofloc ត្រូវការទឹកតិច ប៉ុន្តែកសិករត្រូវការប្រភពទឹកស្អាត និងកែគុណភាពទឹកឱ្យបានសមស្របតាមលក្ខខណ្ឌបច្ចេកទេស ដើម្បីទុកសម្រាប់ផ្លាស់ប្តូរប្រចាំសប្តាហ៍ ដូចនេះត្រូវជ្រើសរើសទីតាំងដែលមានប្រភពទឹកពេញ១ឆ្នាំ។

-ប្រភពអគ្គិសនីមិនគ្រប់គ្រាន់÷ ប្រព័ន្ធខ្យល់ និងម៉ូទ័របូមទឹក គឺត្រូវការប្រើប្រាស់ជាប្រចាំនៅក្នុងអាងចិញ្ចឹមត្រី ជាពិសេសប្រព័ន្ធខ្យល់នៅពេលយប់។ ត្រីទីឡាព្យាក្រហម អាចធន់ទ្រាំពីការដាច់ប្រព័ន្ធខ្យល់ត្រឹមតែ ២ ទៅ៣ម៉ោងប៉ុណ្ណោះ ដូចនេះអ្នកចិញ្ចឹមត្រូវដឹងថា តំបន់របស់ខ្លួនមានបញ្ហាដាច់អគ្គិសនីញឹកញាប់ដែរឬទេ ដើម្បីត្រៀមសម្ភារៈការពារជាមុន(ម៉ាស៊ីនភ្លើងឬបំពាក់ម៉ូទ័រសូឡាជាដើម) ។

-គុណភាពកូនត្រីពូជមិនល្អ៖ សុខភាពខ្សោយ ទំហំកូនមិនស្មើគ្នា បណ្តាលឱ្យការលូតលាស់មិនស្មើគ្នា និងមានអត្រាបាត់បង់ខ្ពស់។ កសិករត្រូវស្គាល់ប្រភព និងពិនិត្យកូនត្រីពូជឱ្យបានច្បាស់លាស់មុនពេលទិញមកចិញ្ចឹម។

-បច្ចេកទេសចិញ្ចឹមមិនច្បាស់លាស់៖ កសិករត្រូវចិញ្ចឹមត្រីតាមលក្ខណៈបច្ចេកទេសឱ្យបានត្រឹមត្រូវទើបទទួលបានជោគជ័យ។ ការចិញ្ចឹមត្រីតាមប្រព័ន្ធ Biofloc បញ្ហាអាចកើតឡើងភ្លាមៗដោយមិននឹកស្មានដល់ ដែលអ្នកចិញ្ចឹមត្រូវធ្វើការគ្រប់គ្រង និងតាមដានជាប្រចាំលើគុណភាពទឹក។

❖ **ហានិភ័យទីផ្សារ៖** ការបាត់បង់ទីផ្សារឬតម្លៃផលិតផលទាបជាងការរំពឹងទុក ដែលជាទូទៅតម្លៃត្រីសាច់តែងប្រែប្រួលមិនច្បាស់លាស់។ កសិករចិញ្ចឹមត្រូវស្វែងរកទីផ្សារឬឈ្មួញប្រមូលទិញឱ្យបានច្រើនកន្លែង ឬចងក្រងជាបណ្តុំអ្នកផលិតដើម្បីភ្ជាប់ខ្សែច្រវាក់ទីផ្សារ។

## ៦-សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានចុះសិក្សាផ្ទាល់ជាមួយកសិករចិញ្ចឹមត្រីទីឡាព្យាក្រហមតាមប្រព័ន្ធ Biofloc នៅខេត្តបន្ទាយមានជ័យ ឃើញថាការចិញ្ចឹមអាចទទួលបានប្រាក់ចំណេញខ្ពស់ជាងការចិញ្ចឹមត្រីទីឡាព្យាក្រហមក្នុងអាងតាមបច្ចេកទេសធម្មតា ពីព្រោះប្រព័ន្ធ Biofloc បានបង្កើតចំណីធម្មជាតិក្នុងអាង និងបានផ្តល់ចំណីផ្សំបន្ថែមទូវគ្រឿងក្នុងមាន់-ទា និងចកអាសូឡា ដែលជាប្រភេទចំណីមានប្រូតេអ៊ីនខ្ពស់សម្រាប់ចិញ្ចឹមត្រី ចូលរួមកាត់បន្ថយការចំណាយចន្លោះពី ១០-១៥% ធៀបទៅនឹងការចិញ្ចឹមតាមធម្មតា ដោយថ្លៃដើមផលិត **៤,៦១១៛/គ.ក**។ បើកសិករលក់ឱ្យឈ្មួញបោះដុំអាចទទួលបានផលចំណេញ **២,៣៨៩៛/គ.ក** បើលក់ឱ្យឈ្មួញលក់រាយក្នុងផ្សារអាចទទួលផលចំណេញ **៤,៣៨៩៛/គ.ក**។ ដូចនេះ កសិករចិញ្ចឹមត្រីទីឡាព្យាក្រហមគួរតែស្វែងរកដៃគូលក់រាយនៅក្នុងផ្សារឱ្យបានច្រើនដើម្បីទទួលបានផលចំណេញខ្ពស់។ ត្រីទីឡាព្យាក្រហមមានតម្រូវការទីផ្សារខ្ពស់ ប៉ុន្តែតម្លៃមានការប្រែប្រួលមិនទៀងទាត់ ដោយសារមានការប្រកួតប្រជែងជាមួយត្រីនាំចូលពីប្រទេសជិតខាង។ ដើម្បីទទួលបានជោគជ័យកសិករត្រូវមានផែនការផលិតច្បាស់លាស់ សាច់ត្រីត្រូវមានគុណភាពល្អ និងមានការភ្ជាប់បណ្តាញទីផ្សារជាមួយឈ្មួញប្រមូលទិញឱ្យបានទៀងទាត់។

**ប្រភពឯកសារសម្រាប់សិក្សាស្រាវជ្រាវ÷**

១-កសិដ្ឋានចិញ្ចឹមត្រីតាមប្រព័ន្ធ Biofloc នៅខេត្តកណ្ដាល និងខេត្តបន្ទាយមានជ័យ

២-បច្ចេកទេសចិញ្ចឹមត្រីតាមប្រព័ន្ធ Biofloc នៅក្នុងគេហទំព័រ You Tub , Facebook និងគេហទំព័រមួយចំនួនទៀតទាំងក្នុង និងក្រៅប្រទេសស្ដីអំពីការចិញ្ចឹមត្រីតាមប្រព័ន្ធ Biofloc រួមមាន÷

-Mahaleap Action: *https://www.youtube.com/@mahaleapac/videos*

-Biodiversity Systems: *https://www.youtube.com/@biodiversitysystems9480/videos*

-កសិដ្ឋាន បាយ អូ (Bio): *https://www.facebook.com/biodiversity.farm*

-SAFAT Farm: *https://www.youtube.com/results?search_query=safat+farm*
-Water Quality: *https://www.intechopen.com/chapters/53211*
-Oem Panha official: *https://www.youtube.com/@oempanhaofficial5831*
-Agri-farming: *https://agrifarming.in/biofloc-fish-feeding-chart-per-body-weight*
-SEAFDEC/Aquaculture Department: *https://www.facebook.com/seafdec.aqd*
-VB Pharma Corporation: *https://vbpharma.vn/blogs/tu-van-ky-thuat*
-Wikipedia: *https://vi.wikipedia.org/wiki/Cá_diêu_hồng*
-FAO (Food and Agriculture Organization of the United Nations). The State of World Fisheries and Aquaculture 2014. *http://www.fao.org*
-Feednavigater: *https://www.feednavigator.com/*
-*https://aouongdidong.com/ao-nuoi-tom/ky-thuat-nuoi-ca-dieu-hong.html*
-Research Grate:*https://www.researchgate.net/publication/*